# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ.០៦៦........../កស

# លិខិតបង្គាប់ការ

**យោង៖**-សេចក្តីសម្រេចលេខ ២៩ សសរ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាលស្តីពីការ បង្កើតគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩ ។

-សេចក្តីសម្រេចលេខ១៣១ សនប ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល ស្តីពីការបង្កើតក្រុមការងារប្រតិបត្តិការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩។

មន្ត្រីរាជការដូចមានរាយនាមខាងក្រោម ត្រូវបានចាត់ជាក្រុមការងារទំនាក់ទំនងហានិភ័យ និងការងារចលនាសហគមន៍នៃជំងឺកូវីដ១៩៖

| | | | |
|---|---|---|---|
| ១-លោកស្រីវេជ្ជបណ្ឌិត | **គេង ស្រី** | អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង | ប្រធាន |
| ២-លោកស្រីវេជ្ជបណ្ឌិត | **ឡាក់ មួយស៊ាង** | អនុប្រធាននាយកដ្ឋានការពារសុខភាព | អនុប្រធាន |
| ៣-លោកវេជ្ជបណ្ឌិត | **ហ៊ឹម សុគ្រី** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៤-លោក | **ម៉ី ប៊ុនរ៉ុង** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៥-លោកវេជ្ជបណ្ឌិត | **កែវ សុគ័ន្ធគ្រា** | ប្រធានមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |
| ៦-លោកវេជ្ជបណ្ឌិត | **គីម សួរគីរុណ** | ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ចាម | សមាជិក |
| ៧-លោកវេជ្ជបណ្ឌិត | **គួយ ប៊ុនធឿន** | ប្រធានមន្ទីរសុខាភិបាលខេត្តកណ្តាល | សមាជិក |
| ៨-លោកវេជ្ជបណ្ឌិត | **អោ វណ្ណថេន** | ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺ | សមាជិក |
| ៩-លោកវេជ្ជបណ្ឌិត | **ប្រាក់ វ៉ុន** | ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ឆ្នាំង | សមាជិក |
| ១០-លោកឱសថការី | **ហៀង គីមសៀត** | ប្រធានការិយាល័យនិយ័តកម្ម នាយកដ្ឋានឱសថ | សមាជិក |
| ១១-លោកស្រីវេជ្ជបណ្ឌិត | **លឹម ខាន់គ្រីភា** | អនុប្រធានការិយាល័យធានាគុណភាពសុខាភិបាល | សមាជិក |
| ១២-លោកវេជ្ជបណ្ឌិត | **លាង ឫទ្ធា** | ប្រធានកម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម | សមាជិក |
| ១៣-លោកវេជ្ជបណ្ឌិត | **មាស សុគន្ធរត្ន** | មន្ត្រីនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង | សមាជិក |
| ១៤-លោក | **អ៊ីច រតនា** | មន្ត្រីនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង | សមាជិក |
| ១៥-លោក | **នៅ មូលិកា** | មន្ត្រីនាយកដ្ឋានការពារសុខភាព | សមាជិក |

**ក្រុមការងារមានភារកិច្ចដូចខាងក្រោម៖**

– រៀបចំផែនការ យុទ្ធសាស្ត្របង្ការហានិភ័យ និងការងារចលនាសហគមន៍ឆ្លើយតបទៅនឹងជំងឺកូវីដ១៩

– ផលិតឧបករណ៍ និងសេចក្តីណែនាំស្តីពីការប្រាស្រ័យទាក់ទងហានិភ័យនិងការងារចលនាសហគមន៍ រួមទាំងការបង្ការការឆ្លង និងការគ្រប់គ្រងកាកសំណល់ជំងឺកូវីដ១៩



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

- ធ្វើការវាយតម្លៃជាប្រចាំ(On going assessment)ឬការវាយតម្លៃរហ័ស ដើម្បីស្វែងរកព័ត៌មានស្តីពី ហានិភ័យនិងក្រុមប្រឈម
- រៀបចំបណ្តុះបណ្តាល ដើម្បីបង្កើនចំណេះដឹងមន្ត្រីសុខាភិបាលអំពី ការប្រាស្រ័យទាក់ទងហានិភ័យ និងការងារចលនាសហគមន៍ រួមទាំងការបង្ការការឆ្លង និងការគ្រប់គ្រងកាកសំណល់ទាក់ទងទៅនឹងជំងឺកូវីដ១៩
- តាមដានព័ត៌មានក្លែងក្លាយ និងឆ្លើយតប
- បំពេញភារកិច្ចផ្សេងៗ តាមការណែនាំរបស់ប្រធានក្រុមការងារប្រតិបត្តិ។

លោក លោកស្រីដែលមានរាយនាមនៅក្នុងក្រុមការងារទំនាក់ទំនងហានិភ័យ និងការងារចលនាសហគមន៍នៃជំងឺកូវីដ១៩ ត្រូវអនុវត្តភារកិច្ច និងការទទួលខុសត្រូវការងារឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហ. ៨រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៦ខែមេសា ឆ្នាំ២០២០

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

វេជ្ជ. ឱ វណ្ណឌីន

**ចម្លងជូន៖**

- រដ្ឋបាលខេត្តពាក់ព័ន្ធ
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- សាម៉ីខ្លួន
- ឯកសារ-កាលប្បវត្តិ